**Embassy of Japan in Cambodia**

# Press Release / Media Invitation

No. 20 PR-26/EoJ 03 July 2026

## Tanabata Festival 2026

The Embassy of Japan, in collaboration with the Cambodia-Japan Cooperation Center (CJCC) and the Japan Foundation, Phnom Penh Liaison Office, will host the **Tanabata Festival 2026** from **10 to 12 July** at CJCC. This traditional event, held annually since 2004, aims to further promote cultural exchange between Japan and Cambodia.

The Embassy of Japan cordially invites all interested media representatives to attend and cover the **opening ceremony** on **Friday, 10 July 2026**, from **18:00 to 19:30** (doors open at **17:30**) at the **Angkor-Kizuna Hall, CJCC**, as well as other events throughout the festival. * *Please arrive at the venue 30 minutes before the event starts.* (Click to see Map to CJCC).

The tentative agenda of opening ceremony is enclosed. Other events are introduced in the pamphlet with the detailed programs on this website: the Event Pamphlet) or on the official event page: Japan Cambodia Kizuna & Tanabata.

The festival will feature a variety of cultural workshops and performances from both Japan and Cambodia, including *Special Stage by TANABATA Anime Song & Street Dance Unit* (11 July, 14:30-15:30) and *NODOJIMAN Japanese Song Contest 2026* (12 July, 15:00-17:30). Participants can also enjoy Tanabata traditions, such as writing wishes on colorful strips of paper and tying them to bamboo branches.

***Honorable Presence of This Year's Sponsors:**

**Gold Sponsors:**

SATHAPANA Bank Plc., Air Cambodia Co., Ltd., AEON GROUP: AEON MALL (Cambodia) CO., LTD., AEON (CAMBODIA) CO., LTD., AEON Specialized Bank (Cambodia) Plc., Branch of AEON Delight (Vietnam) Company Limited.

**Silver Sponsors:**

BUDDY'S MARKETING JP CO., LTD. and STARTS (CAMBODIA) CORPORATION.

**Bronze Sponsors:**
J Trust Royal Bank Plc., Active People's Microfinance Institution Plc., Panasonic Cambodia (Branch of Panasonic Asia Pacific Pte. Ltd.), Genki Sushi.

Tanabata, also known as the Star Festival, is a traditional Japanese celebration held annually on 7 July. It tells the romantic tale of two celestial lovers, Orihime (a weaver princess) and Hikoboshi (a cowherd), who are separated by the Amanogawa (the Milky Way) and allowed to meet only once a year, on this special day. To commemorate the occasion, people in Japan write their wishes on colorful paper strips and hang them on bamboo trees, hoping their dreams will come true. We warmly invite people from all over Cambodia to join in and celebrate this cultural event together!

Advance registration is required for media representatives. For registration and inquiries, please contact the Culture and Information Section at 023 217 161 (Ext: 1121) or email: info.jpn@pp.mofa.go.jp

---


*Embassy of Japan in Cambodia*

*Tel: 023 217 161*

*Email: info.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*

ស្ថានទូតជប៉ុនប្រចាំកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន
# និងលិខិតអញ្ជើញអ្នកសារព័ត៌មាន

No. 20 PR-26/EoJ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៦

## ពិធីបុណ្យផ្កាយ ឬ តាណាបាតា ២០២៦

ស្ថានទូតជប៉ុន រួមសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) និងមូលនិធិជប៉ុន ការិយាល័យទំនាក់ទំនងភ្នំពេញ នឹងរៀបចំនូវព្រឹត្តិការណ៍ពិធីបុណ្យផ្កាយ ឬ តាណាបាតា ឆ្នាំ២០២៦ នៅថ្ងៃទី១០-១២ ខែកក្កដា នៅCJCC។ ជាក់ស្តែង ពិធីបុណ្យផ្កាយត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០០៤មក ក្នុងគោលបំណងបន្តជម្រុញការផ្លាស់ប្តូរវប្បធម៌រវាងប្រទេសជប៉ុន និងកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ស្ថានទូតជប៉ុន សូមគោរពអញ្ជើញអ្នកសារព័ត៌មានទាំងអស់ដែលចាប់អារម្មណ៍ចូលរួមយកព័ត៌មានក្នុងពិធីបើកនៅ**ថ្ងៃសុក្រ ទី១០ ខែកក្កដា ឆ្នាំ២០២៦ ចាប់ពីម៉ោង ៦.០០នាទីល្ងាច ដល់ម៉ោង ៧.៣០នាទីល្ងាច នៅសាលអង្គរ-គីហ្សូណា CJCC** (បើកទទួលស្វាគមន៍ចាប់ពីម៉ោង៥.៣០នាទីល្ងាច) ព្រមទាំងកម្មវិធីផ្សេងៗទៀតក្នុងអំឡុងព្រឹត្តិការណ៍តាណាបាតានេះកុំបីខាន។ *សូមមកដល់ទីតាំង៣០នាទីមុនកម្មវិធីចាប់ផ្តើម (សូបចុបស្វែងរក ទីតាំងផែនទីCJCC)

មានភ្ជាប់ជូនព័ត៌មានកម្មវិធីបើក និងព័ត៌មានលម្អិតនៃកម្មវិធីនានាក្នុងព្រឹត្តិការណ៍តាណាបាតា មានលើគេហទំព័រនេះ៖ ព័ត៌មានកម្មវិធីលម្អិត ឬអាចស្វែងរកបានតាមទំព័រហ្វេសប៊ុកផ្លូវការ ព្រឹត្តិការណ៍តាណាបាតានេះ Japan Cambodia Kizuna & Tanabata ។

ព្រឹត្តិការណ៍តាណាបាតានេះនឹងមានការបង្ហាញជូននូវសិក្ខាសាលាវប្បធម៌ និងការសម្តែងសិល្បៈយ៉ាងសម្បូរបែបពីសំណាក់ប្រទេសជប៉ុន និងកម្ពុជា រួមមានឆាកសម្តែងពិសេសដោយ បទចម្រៀងគំនូរជីវចល TANABATA និងក្រុមរាំសម្តែងតាមផ្លូវ (ថ្ងៃទី១១ ខែកក្កដា វេលាម៉ោង ១៤:៣០-១៥:៣០) និងការប្រឡងចម្រៀងណូដូជីម៉ាន់២០២៦ (ថ្ងៃទី១២ ខែកក្កដា វេលាម៉ោង ១៥:០០-១៧:៣០)។ អ្នកចូលរួម ក៏នឹងទទួលយកនូវបទពិសោធន៍នៃទំនៀមទម្លាប់ក្នុងពិធីបុណ្យនេះ ដូចជា ការសរសេរបំណងប្រាថ្នាលើចម្រៀកក្រដាសពណ៌ ហើយចងព្យួរនឹងមែកឫស្សី។

ឆ្នាំនេះ ក្រុមហ៊ុនចូលរួមសហការឧបត្ថម្ភមានដូចតទៅ៖

អ្នកឧបត្ថម្ភធំមាន៖ ធនាគារ ស្ថាបនា, ក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា, ធនាគារ ស្ថាបនា, ក្រុមហ៊ុន និង អ៊ីអនគ្រុប៖ អ៊ីអន ម៉ល (ខេមបូឌា) ខូ អិលធីឌី, អ៊ីអន (ខេមបូឌា) ខូ អិលធីឌី, ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី, សាខាក្រុមហ៊ុន អ៊ីអន ឌីឡៃប៍ (វៀតណាម) ខមភេនី លីមីធីត។

អ្នកសហការឧបត្ថម្ភធំមាន៖ ក្រុមហ៊ុនបាឌី ម៉ាឃីធីង ជេភី ឯ.ក និងស្កាត (ខេមបូឌា) ខបភើរេសិន។

អ្នកឧបត្ថម្ភមាន៖ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក, គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី សាខាក្រុមហ៊ុនប៉ាណាសូនិក អេស៊ា ផេស៊ីហ្វិក ភីធីអ៊ី អិលធីឌី និង Genki Sushi។

ពិធីបុណ្យផ្កាយ ឬ តាណាបាតា គឺជាកម្មវិធីបុណ្យប្រពៃណីជប៉ុន ដែលតែងតែប្រារព្ធឡើងនៅថ្ងៃទី៧ ខែកក្កដា ជារៀងរាល់ឆ្នាំនៅប្រទេសជប៉ុន ដើម្បីរំឭកដល់ដំណើររឿងរបស់គូស្នេហ៍នៅលើឋានសួគ៌មួយគូ គឺនារីតម្បាញ (អូរិហ៊ីមិ) និងបុរសគង្វាលគោ (ហ៊ីកុបុស៊ិ) ដែលតាមតំណាលរឿង គូស្នេហ៍មួយគូនេះ ត្រូវបានបំបែកដោយទន្លេអាម៉ាណុហ្គាវ៉ា ហើយអាចជួបគ្នាបានតែម្តងគត់ក្នុងមួយឆ្នាំ គឺនៅថ្ងៃទី៧ ខែកក្កដា។ ដូច្នេះនៅក្នុងថ្ងៃនោះ ប្រជាជនជប៉ុននាំគ្នាសរសេរបំណងប្រាថ្នារបស់ខ្លួនលើចម្រៀកក្រដាស ហើយចងព្យួរទៅនឹងមែកឫស្សីដើម្បីបួងសួងឱ្យបានសម្រេចតាមអ្វីដែលខ្លួនប៉ងប្រាថ្នា។ យើងសូមស្វាគមន៍ប្រជាជនមកពីទូទាំងប្រទេសកម្ពុជា ចូលរួមប្រារព្ធពិធីនេះជាមួយគ្នា!

ដើម្បីចូលរួមព្រឹត្តិការណ៍តាណាបាតា តម្រូវឱ្យអ្នកសារព័ត៌មានចុះឈ្មោះជាមុន។ សម្រាប់ការចុះឈ្មោះ និងសាកសួរព័ត៌មាន សូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈលេខទូរសព្ទ៖ ០២៣ ២១៧ ១៦១ (លេខភ្ជាប់បន្ត ១១២១) ឬ អ៊ីម៉ែល៖ info.jpn@pp.mofa.go.jp។

---